លោកអ្នកប្រហែលជាមានសិទ្ធិទទួលកិច្ចជួយបង្វែរ

កិច្ចជួយបង្វែរ (Diversion Services) អាចផ្តល់ជូនលោកអ្នកជាប្រាក់ឬក៏កិច្ចជួយដែលមិនមែនជាប្រាក់ដើម្បីបំពេញនូវសេចក្តីត្រូវការក្នុងពេលបច្ចុប្បន្នដ៏ជាក់លាក់ ឬក៏ការមានអាសន្នមួយ ។ សូមអានសន្លឹកពត៌មាននេះដោយប្រុងប្រយ័ត្ន ។ សន្លឹកនេះអាចផ្តល់ជូននូវពត៌មានដែលអាចជួយចំពោះលោកអ្នកសំរេច ថាតើកិច្ចជួយបង្វែរនេះត្រឹមត្រូវចំពោះលោកអ្នកឬទេ ។ លោកអ្នកត្រូវតែបំពេញនិងចុះហត្ថលេខានៅលើកិច្ចព្រមព្រៀងជាមួយកិច្ចជួយបង្វែរ (Diversion Services Agreement) នៅមុនពេលដែលលោកអ្នកអាចទទួលកិច្ចជួយបង្វែរនេះ ។

ពត៌មានអំពីកិច្ចជួយបង្វែរ

- ខណ្ឌកំណត់ថាតើលោកអ្នកមានសិទ្ធិទទួលកិច្ចជួយបង្វែរឬទេ ។ កិច្ចជួយបង្វែរនេះគឺ**សំរាប់តែ**មនុស្សណាដែល :
  - អាចទទួលនូវផលប្រយោជន៍ពីកិច្ចជួយបង្វែរនេះ និងអាចចៀសវាងសេចក្តីត្រូវការទទួលប្រាក់ជំនួយជារាល់ខែ **និង**
  - បង្ហាញថាជាអ្នកមានសិទ្ធិទទួលប្រាក់ជំនួយ **និង**
  - ត្រូវការជំនួយជាប្រាក់ខ្ទះ និងមិនមែនជាប្រាក់ខ្ទះដើម្បីជួយដោះស្រាយសេចក្តីត្រូវការក្នុងពេលបច្ចុប្បន្ន ឬស្ថានភាពពេលមានអាសន្ន ។
- លោកអ្នកអាចបានទទួលកិច្ចជួយបង្វែរនេះ**តែ**នៅពេលណាដែលលោកអ្នកដាក់ពាក្យសុំ ។ បើសិនជាលោកអ្នកជ្រើសរើសទទួលប្រាក់ជំនួយលោកអ្នកនឹងមិនមានសិទ្ធិទទួលកិច្ចជួយបង្វែរឡើយ ។
- លោកអ្នកគួ**រតែជ្រើសរើស**ដើម្បីទទួលកិច្ចជួយបង្វែរនេះ បើសិនជាលោកអ្នកមិនត្រូវការ ឬមិនចង់បានប្រាក់ជំនួយនៅក្នុងខែនីមួយ។ ។
- លោកអ្នកប្រហែលជាអាចមានសិទ្ធិទទួលបណ្ណាទិញម្ហូប និងជំនួយមេឌី-ខាល និងលោកអ្នកប្រហែលជាអាចទទួលកិច្ចជួយសំរាប់ការថែទាំកុមារ ។
- លោកអ្នកហើយនិងខណ្ឌត្រូវតែព្រមព្រៀងនៅលើរបៀបបង់ប្រាក់ឱ្យសំរាប់កិច្ចជួយបង្វែរនេះ ។

ជ្រើសរើសកិច្ចជួយបង្វែរជំនួសប្រាក់ជំនួយប្រចាំខែ

បើសិនជាលោកអ្នកជ្រើសរើសទទួលកិច្ចជួយបង្វែរ :

- លោកអ្នកនឹងមិនបានទទួលប្រាក់ជំនួយ**ប្រចាំខែ**ឡើយ ។
- លោកអ្នកត្រូវតែចុះហត្ថលេខានៅលើសំណៅកិច្ចព្រមព្រៀងជាមួយកិច្ចជួយបង្វែរ (Diversion Services Agreement) ដែលដាក់ភ្ជាប់ជាមួយនេះ ។
- លោកអ្នកនឹងទទួលសេចក្តីប្រកាសមួយដែល :
  - បដិសេធពាក្យដាក់សុំប្រាក់ជំនួយក្នុងពេលបច្ចុប្បន្នរបស់លោកអ្នក **និង**
  - ជំរាបលោកអ្នកអំពីរបៀបដែលប្រាក់បង់សំរាប់កិច្ចជួយបង្វែររបស់លោកអ្នក និងចំនួនខែនៃកំឡុងពេលកិច្ចជួយបង្វែររបស់លោកអ្នក ។
- លោកអ្នកនឹងទទួលសេចក្តីប្រកាសយល់ព្រម ឬក៏បដិសេធមួយដោយឡែកសំរាប់ជំនួយផ្សេងទៀតដែលលោកអ្នកបានដាក់ពាក្យសុំ ដូចជា បណ្ណាទិញម្ហូប និងជំនួយមេឌី-ខាល ។
- លោកអ្នកត្រូវតែប្រាប់អ្នកកាន់សំណុំរឿងរបស់លោកអ្នក បើសិនជាលោកអ្នកត្រូវការជំនួយសំរាប់កិច្ចថែទាំកុមារ នៅក្នុងកំឡុងពេលនៃកិច្ចជួយបង្វែររបស់លោកអ្នក ។

បន្ទាប់ពីបានទទួលកិច្ចជួយបង្វែរ

បើសិនជាលោកអ្នកដាក់ពាក្យសុំប្រាក់ជំនួយបន្ទាប់ពីទទួលកិច្ចជួយបង្វែរ និង :

- <u>នៅមុនពេលដែលកំឡុងពេលនៃកិច្ចជួយបង្វែរបញ្ចប់</u> លោកអ្នកត្រូវតែជ្រើសរើសឱ្យខណ្ឌអនុវត្តតាមវិធានការណាមួយដូចខាងក្រោមនេះ :
  - បន្ថយប្រាក់ជំនួយប្រចាំខែរបស់លោកអ្នកតាមចំនួនដែលបានកំណត់ដោយខណ្ឌដើម្បីបង់សងប្រាក់បង់សំរាប់កិច្ចជួយបង្វែរ/កិច្ចការ **ឬ**
  - គិតបញ្ចូលកំឡុងពេលសរុបនៃកិច្ចជួយបង្វែរទៅលើចំនួនកម្រិតពេល៦០ខែរបស់លោកអ្នក ។
- <u>បន្ទាប់ពីបញ្ចប់កំឡុងពេលនៃកិច្ចជួយបង្វែរ</u> ខណ្ឌនឹងរាប់បញ្ចូលតែចំនួនពេលមួយខែ នៃកំឡុងពេលកិច្ចជួយបង្វែរទៅលើចំនួនកម្រិតពេល៦០ខែរបស់លោកអ្នកតែប៉ុណ្ណោះ ។

ការគិតរកចំនួនកំឡុងពេលនៃកិច្ចជួយបង្វែរ

នៅពេលដែលខណ្ឌគិតរកកំឡុងពេលនៃកិច្ចជួយបង្វែរ ខណ្ឌ :

- កំណត់អំពីតម្លៃទិញ ឬតម្លៃនៅក្នុងពេលបច្ចុប្បន្ននៃកិច្ចជួយដែលមិនមែនជាប្រាក់ដែលលោកអ្នកទទួល ។
- ដកចំនួននៃប្រាក់បង់សំរាប់កិច្ចជួយបង្វែរ/កិច្ចការ និងចែកចំនួននេះដោយចំនួនប្រាក់ជំនួយច្រើនបំផុតរបស់លោកអ្នកសំរាប់ក្រុមគ្រួសារទទួលជំនួយរបស់លោកអ្នក នៅក្នុងពេលដែលលោកអ្នកបានទទួលកិច្ចជួយបង្វែរ ។

ឧទាហរណ៍នៃការគិតរកកំឡុងពេលនៃកិច្ចជួយបង្វែរ

- អ្នកដាក់ពាក្យសុំមានកូនពីរនាក់ទទួលប្រាក់ចំនួន$1,375 ដើម្បីយកមកជួសជុលថែទាំរថយន្តនៅពេលមានអាសន្ន ដែលអ្នកស្រីនោះអាចបន្តទៅធ្វើការ ។
- ជាមួយប្រាក់ជំនួយច្រើនបំផុតចំនួន $596 សំរាប់ក្រុមគ្រួសារទទួលជំនួយរបស់គាត់ដែលមានគ្នាបីនាក់នៅក្នុងពេលដែលអ្នកស្រីនេះទទួលកិច្ចជួយបង្វែរ ចំនួនកំឡុងពេលនៃកិច្ចជួយបង្វែរគឺមានពីរខែ ($1,375 ត្រូវបានចែកដោយ $596 = 2.3 ខែដែលគេបានសម្រួលបន្ថយទៅចំនួន៣កំឡុងពេលកិច្ចជួយបង្វែរ ចំនួនពីរខែ) ។

បើសិនជាលោកអ្នកមិនបានជ្រើសរើសថាចង់ទទួលកិច្ចជួយបង្វែរនេះទេ សូមប្រាប់ខណ្ឌារបស់លោកអ្នកថាលោកអ្នកចង់ទទួលប្រាក់ជំនួយប្រចាំខែ បើសិនជាលោកអ្នកមានសិទ្ធិទទួល ។

កិច្ចព្រមព្រៀងទទួលកិច្ចជួយបង្វែរ (Diversion Services)
កម្មវិធីជួយឱ្យធ្វើការនិងទទួលខុសត្រូវចំពោះកូនតែរដ្ឋការីហ្វ៉ារនីញ៉ា (CalWORKs Program)

សំណុំរឿងឈ្មោះ	លេខសំណុំរឿង	ឈ្មោះអ្នកកាន់សំណុំរឿង	លេខអ្នកកាន់សំណុំរឿង

សំរាប់តែអ្នកកាន់សំណុំរឿងបំពេញ (WORKER COMPLETES) :

☐ Cash payment in the amount of: $_____ for the following need: _____

_____

☐ Non-cash services: The purchase price or current value for the non-cash services is: $_____

Describe non-cash services: _____

☐ The diversion period will be from _____ (DATE) to _____ (DATE).

សំរាប់អ្នកដាក់ពាក្យសុំបំពេញ

ខ្ញុំយល់ព្រមជ្រើសរើសយកកិច្ចជួយបង្វែរពីព្រោះតែខ្ញុំមិនត្រូវការ ឬចង់បានប្រាក់ជំនួយសំរាប់ខែនីមួយៗ ប៉ុន្តែខ្ញុំត្រូវការប្រាក់ខ្ចី ឬកិច្ចជួយនានាដែលមិនមែនជាប្រាក់ក្នុងពេលឥឡូវនេះ ដើម្បីដោះស្រាយសេចក្ដីត្រូវការសំរាប់ស្ថានភាពក្នុងពេលបច្ចុប្បន្ន ឬក្នុងពេលមានអាសន្ន ។ ខណ្ឌហើយនិងខ្ញុំយល់ព្រមទៅលើវិធីបង់ប្រាក់ឱ្យដូចមាននៅខាងលើ ។

សូមសរសេរហត្ថលេខាសង្ខេបជាអក្សរដើមនៃឈ្មោះ

_____ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានអានសន្លឹកពត៌មាននៃកិច្ចជួយបង្វែរ ។ ខ្ញុំយល់អំពីច្បាប់ និងការទទួលខុសត្រូវរបស់ខ្ញុំសំរាប់ការជ្រើសរើសកិច្ចជួយបង្វែរ ជាជំនួសការទទួលប្រាក់ជំនួយសំរាប់ខែនីមួយៗ ។

ខ្ញុំក៏យល់ដែរថា :

_____ ខ្ញុំនឹងទទួលសេចក្ដីប្រកាសបដិសេធពាក្យដាក់សុំប្រាក់ជំនួយនៅក្នុងពេលបច្ចុប្បន្នរបស់ខ្ញុំ ហើយនិងប្រាប់ខ្ញុំអំពីរបៀបដែលប្រាក់បង់សំរាប់កិច្ចជួយបង្វែររបស់លោកអ្នក និងចំនួនខែនៃកំឡុងពេលក្នុងកិច្ចជួយបង្វែររបស់ខ្ញុំ ។

- នៅពេលគិតរកកំឡុងពេលនៃកិច្ចជួយបង្វែរ ខណ្ឌយកចំនួននៃប្រាក់បង់សំរាប់កិច្ចជួយបង្វែរ/កិច្ចការ និងចែកចំនួននេះដោយចំនួនប្រាក់ជំនួយច្រើនបំផុតរបស់លោកអ្នក សំរាប់ក្រុមគ្រួសារទទួលជំនួយរបស់លោកអ្នក នៅក្នុងពេលដែលលោកអ្នកបានទទួលកិច្ចជួយបង្វែរ ។
- នៅពេលគិតរកកំឡុងពេលនៃកិច្ចជួយបង្វែររបស់ខ្ញុំ ខណ្ឌកំណត់អំពីតម្លៃទិញ/តម្លៃនៅក្នុងពេលបច្ចុប្បន្ន សំរាប់កិច្ចជួយដែលមិនមែនជាប្រាក់ ។

_____ ខ្ញុំនឹងទទួលសេចក្ដីប្រកាសយល់ព្រម ឬក៏បដិសេធមួយដោយឡែក សំរាប់ជំនួយដទៃទៀតដែលលោកអ្នកបានដាក់ពាក្យសុំ ដូចជា បណ្ណាទិញម្ហូប និងជំនួយមេឌី-ខាល ។

_____ បើសិនជាខ្ញុំដាក់ពាក្យសុំ និងគេបានឃើញថាខ្ញុំមានសិទ្ធិទទួលប្រាក់ជំនួយ<u>នៅមុនពេល</u>បញ្ចាប់នៃកំឡុងពេលកិច្ចជួយបង្វែររបស់ខ្ញុំ ខ្ញុំត្រូវប្រាប់ខណ្ឌថាខ្ញុំជ្រើសរើសយកវិធីណាមួយដូចខាងក្រោម :

- បង់សងតម្លៃជាប្រាក់នៃកិច្ចជួយបង្វែរដោយបន្ថយប្រាក់ជំនួយប្រចាំខែរបស់ខ្ញុំតាមចំនួនដែលបានកំណត់ដោយខណ្ឌ **ឬក៏**
- គិតបញ្ចូលចំនួនខែនៅក្នុងកំឡុងពេលនៃកិច្ចជួយបង្វែររបស់ខ្ញុំទៅលើចំនួនកម្រិតពេលច្រើនបំផុត៦០ខែនៃពេលដែលខ្ញុំមានសិទ្ធិទទួលជំនួយ ។

_____ បើសិនជាខ្ញុំដាក់ពាក្យសុំប្រាក់ជំនួយ និងខ្ញុំត្រូវបានដឹងថាមានសិទ្ធិទទួលជំនួយ<u>បន្ទាប់ពី</u>បញ្ចាប់កំឡុងពេលនៃកិច្ចជួយបង្វែរ ខណ្ឌនឹងរាប់បញ្ចូលតែចំនួនពេលតែមួយខែទៅលើចំនួនកម្រិតពេល៦០ខែរបស់ខ្ញុំ ។ គឺមិនមានតម្រូវឱ្យបង់ប្រាក់សងវិញឡើយ ។

ហត្ថលេខាឪពុកម្តាយ ឬអ្នកថែរក្សាជាសាច់ញាតិ	កាលបរិច្ឆេទ
ហត្ថលេខានៃម្ចាស់ប្រពន្ធពេញវ័យ ឬឪពុកម្តាយម្ខាងទៀត (បើសិនជារស់នៅក្នុងផ្ទះ)	កាលបរិច្ឆេទ
ហត្ថលេខាសាក្សីទៅលើគំនូសសំគាល់ ឬអ្នកបកប្រែ ឬមនុស្សដទៃទៀតដែលបំពេញសំណៅ	កាលបរិច្ឆេទ

ខ្ញុំសូមបញ្ជាក់ថាឪពុកម្តាយ/អ្នកថែរក្សាជាសាច់ញាតិត្រូវបានផ្តល់ឱ្យសេចក្ដីចម្លងនៃសំណៅ CW 88 “Coversheet and Diversion Services Agreement. (ពត៌មាននិងកិច្ចព្រមព្រៀងសំរាប់កិច្ចជួយបង្វែរ)” មួយច្បាប់ ។ ឪពុកម្តាយ/អ្នកថែរក្សាជាសាច់ញាតិថ្លែងថា គាត់យល់ច្បាប់ទាំងនេះ ហើយនិងការទទួលខុសត្រូវរបស់គាត់ដើម្បីជ្រើសរើសកិច្ចជួយបង្វែរជំនួសការទទួលប្រាក់ជំនួយប្រចាំខែ ។ ឪពុកម្តាយ/អ្នកថែរក្សាជាសាច់ញាតិក៏បានថ្លែងថា គាត់យល់អំពីច្បាប់នៃកំឡុងពេលសំរាប់កិច្ចជួយ<u>ប</u>ង្វែរនេះដែរ ។

ហត្ថលេខាអ្នកកាន់សំណុំរឿង	កាលបរិច្ឆេទ

សំរាប់តែខណ្ឌបំពេញ

Diversion Period Calculation:

Diversion Amount $_____ ÷ AU MAP $ _____ = _____ months. *(Exclude partial months.)*